គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤

# សម្លឹងមើលលទ្ធផលនៃការបោះឆ្នោត ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ប្រកាន់ជំហរមិនចូលរួម និងមិនគាំទ្រការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ក្រោមជាតិរួមមាន ការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ការបោះឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ដោយនៅតែបន្តចាត់ទុកថា នេះជាការបោះឆ្នោតដែលមិនមានតម្លាភាព និងគ្មានអត្ថន័យ។ ប្រព័ន្ធបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នេះ មិនបានឆ្លុះបញ្ចាំងភាពត្រឹមត្រូវក្នុងការចូលរួមប្រកួតប្រជែង ព្រោះលទ្ធផលនៃការបោះឆ្នោត យើងអាចដឹងមុនតាមរយៈ ការគណនាចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ របស់គណបក្សនីមួយៗ។ ជាក់ស្តែងណាស់ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ទី១៨ ខែឧសភា ឆ្នាំ២០១៤ មានតែ ៥ គណបក្សនយោបាយប៉ុណ្ណោះ បានចូលរួមប្រកួតប្រជែងការបោះឆ្នោត បើទោះបីជាមាន ៦ គណបក្សនយោបាយ ដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំសង្កាត់ក៏ដោយ។

មានគណបក្សនយោបាយចំនួន ៥ បានចុះបញ្ជីបេក្ខជនឈរឈ្មោះ នៅតាមមណ្ឌលឈរឈ្មោះបោះឆ្នោតរួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ គណបក្សនយោបាយដែលមានសមាសភាពក្នុងក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣(បច្ចុប្បន្ន)នេះ មានចំនួន ៦គណបក្ស។ គណបក្សនយោបាយមួយចំនួនបានប្រកាសបញ្ចូលគ្នាសម្រាប់ការបោះឆ្នោតនេះ ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់របស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សនឹងបោះឆ្នោតឲ្យបេក្ខជន គណបក្សសង្គ្រោះជាតិ រីឯគណបក្សជាតិនិយម (អតីតគណបក្សនរោត្តមរណឫទ្ធិ) និងគណបក្សសញ្ជាតិកម្ពុជាមិនចូលរួមប្រកួតប្រជែងការបោះឆ្នោតនេះទេ។ គួរកត់សម្គាល់ថា គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ ដែលបានចូលរួមប្រកួតប្រជែងការបោះឆ្នោតនេះមិនមានសមាជិកក្រុមប្រឹក្សាឃុំសង្កាត់នោះទេ។

តាមច្បាប់បោះឆ្នោតបច្ចុប្បន្ន បេក្ខជនដែលមានសិទ្ធិឈរឈ្មោះបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ មានសញ្ជាតិខ្មែរពីកំណើត មានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អនុញ្ញាតឱ្យគណបក្សនយោបាយ

ទស្សនៈវិស័យ ៖ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។
Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.



ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ឃោសនាបោះឆ្នោតចំនួន ១៥ ថ្ងៃ ចាប់ពីម៉ោង ៦ព្រឹក ដល់ម៉ោង ១០យប់ តែត្រូវបានហាមឃាត់នូវការប្រើប្រាស់ឧបករណ៍បំពងសម្លេងចាប់ពីម៉ោង ១២ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល។ សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ ម៉ោង មុនថ្ងៃបោះឆ្នោត។ ប្រព័ន្ធបោះឆ្នោតនេះបញ្ចូលគ្នារវាងប្រព័ន្ធអសកលជាមួយប្រព័ន្ធសមាមាត្រ គណបក្សបញ្ជី )បិទ( ។ មានតែសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងមុខតំណែង ជាអង្គបោះឆ្នោតសម្រាប់ការបោះឆ្នោតនេះ។ បេក្ខជននៅក្នុងបញ្ជីត្រូវបានជ្រើសរើសដោយគណបក្ស ដែលមិនមានលក្ខណៈបើកចំហរ ឲ្យមានការដាក់ពាក្យពីបេក្ខជនខាងក្រៅ។

ការចំណាយ និងថវិកាសម្រាប់រៀបចំការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនេះ គឺជាការខ្ជះខ្ជាយថវិកាជាតិ ព្រោះការបោះឆ្នោតតាមប្រព័ន្ធនេះ ស្មើនឹងការចាត់តាំង ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយគណបក្សនយោបាយ។ ជាឱកាសគណបក្សនយោបាយអាចដាក់បេក្ខជនជាស្ត្រី និងយុវជនឲ្យបានច្រើនដើម្បីជាប់ជាសមាជិកក្រុមប្រឹក្សាទាំងនេះ។ ចំនួនអាសនៈសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សម្រាប់គណបក្សណាមួយអាចគណនាដោយយោងតាមចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់នៃគណបក្សនោះមាន។

តាមការបញ្ជាក់របស់មន្ត្រី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ស្ថាប័នបោះឆ្នោតមួយនេះនឹងត្រូវចំណាយថវិកាចំនួនជាង ១,៧ លានដុល្លារ សម្រាប់រៀបចំការបោះឆ្នោត ដោយមានអ្នកចូលរួមបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងមុខតំណែងសរុបទូទាំងប្រទេសចំនួន ១១.៤៥៩នាក់ ដើម្បីជ្រើសរើសអាសនៈ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានចំនួន ២៩៣១អាសនៈ និងអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ចំនួន ៣៩៣អាសនៈ។

ប្រព័ន្ធបោះឆ្នោតអាចឲ្យគេធ្វើការគណនាបានជាមុននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៤។

*យោងតាមរបាយការណ៍លទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ ឆ្នាំ២០១២ ចេញដោយ គ.ជ.ប បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ ៧២.៣៦% (៨២៩២អាសនៈ) នៃអាសនៈសរុបទូទាំងប្រទេស ១១៤៥៩អាសនៈ រីឯគណបក្សសង្គ្រោះជាតិទទួលបាន ២៥.៧៩% (២៩៥៥អាសនៈ) គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ១.៣២% (១៥១អាសនៈ) គណបក្សជាតិនិយម ទទួលបាន ០.៤៥% (៥២អាសនៈ) គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទទួលបានចំនួន ០.០៧% (៨អាសនៈ) និងគណបក្សសញ្ជាតិកម្ពុជា មានចំនួន ១អាសនៈ។*

## *លទ្ធផលប៉ាន់ប្រមាណនៃការបោះឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ*

ក្នុងករណីគណបក្សជាតិនិយម ចូលរួមប្រកួតការបោះឆ្នោត នោះលទ្ធផលធៀបអាសនៈសរុបទូទាំងប្រទេសគឺ គណបក្សប្រជាជនកម្ពុជាទទួលបាន ២២១៦អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន ៦៧៩ អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ១៩អាសនៈ គណបក្សជាតិនិយម ទទួលបាន ១អាសនៈ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទទួលបាន ១អាសនៈ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មិនទទួលបានអាសនៈទេ និងនៅសល់ចំនួន ១៥អាសនៈ (ដោយមានសន្លឹកឆ្នោតស្មើគ្នា) ត្រូវធ្វើការចាប់ឆ្នោត។


ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

អាសនៈទាំង ១៥ ដែលនៅសល់សម្រាប់ធ្វើការចាប់ឆ្នោតមាននៅក្នុងខេត្តបន្ទាយមានជ័យ មាន២អាសនៈ ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបងមានចំនួន ៣អាសនៈ ដែលក្នុងនោះ ស្រុកឯកភ្នំចំនួន១ស្រុកសង្កែចំនួន១ និងស្រុកសំពៅលូនចំនួន១ ខេត្តកំពង់ចាម ចំនួន១ នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ធំចំនួន១ នៅក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកណ្ដាលចំនួន១ នៅក្នុងស្រុកកៀនស្វាយ ខេត្តក្រចេះចំនួន១ នៅក្នុងស្រុកសំបូរ ខេត្តព្រះវិហារចំនួន២ ដែលក្នុងនោះ ស្រុកត្បែងមានជ័យ ចំនួន១ និងស្រុកព្រះវិហារ ចំនួន១ ខេត្តរតនគិរីចំនួន១ នៅក្នុងស្រុកបានលុង ខេត្តសៀមរាបចំនួន១ ក្នុងស្រុកសូត្រនិគម និងខេត្តត្បូងឃ្មុំចំនួន១ ក្នុងស្រុកពញាក្រែក។ អាសនៈនៅសល់ទាំងអស់នេះ ភាគច្រើនគឺចាប់ឆ្នោតរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

បើក្នុងករណីគណបក្សជាតិនិយមធ្វើការគាំទ្រទៅឲ្យគណបក្សហ្វ៊ុនស៊ិនប៉ិច នោះលទ្ធផលបានបង្ហាញថា គណបក្សប្រជាជនទទួលបាន ២២១១អាសនៈ ថយចុះចំនួន ៥អាសនៈ គណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបាន ២៦អាសនៈ កើនឡើងចំនួន ៧អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន ៦៧៩អាសនៈ ដោយមិនមានអ្វីប្រែប្រួល និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ទទួលបាន១អាសនៈ រីឯគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មិនទទួលបានលទ្ធផលអ្វីទាំងអស់ ជាមួយអាសនៈនៅសល់ចំនួន១៤ ដែលត្រូវធ្វើការចាប់ឆ្នោតរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលមានសម្លេងឆ្នោតស្មើគ្នា។

*មានការប្រែប្រួលលទ្ធផលតិចតួចបំផុតសម្រាប់គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ* គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ប្រសិនបើក្រុមប្រឹក្សាឃុំសង្កាត់របស់គណបក្សជាតិនិយមបោះជូនឲ្យគណបក្សចូលរួមការប្រកួតប្រជែងណាមួយ។ សមាជិកក្រុមប្រឹក្សាគណបក្សជាតិនិយមនេះ អាចបោះឆ្នោតឲ្យគណបក្សសង្គ្រោះជាតិ ព្រោះថាសមាជិកគណបក្សនេះបានប្រកាសក្នុងកម្មវិធីវិទ្យុ បានអំពាវនាវឲ្យអង្គបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួន ឲ្យបោះឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិ។

បើក្នុងករណីគណបក្សជាតិនិយមធ្វើការគាំទ្រទៅឲ្យគណបក្សសង្គ្រោះជាតិ នោះលទ្ធផលបានបង្ហាញថាគណបក្សប្រជាជនកម្ពុជាទទួលបាន ២២០៨អាសនៈ គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាន ១៩អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន ៦៩០អាសនៈ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ទទួលបាន ១ អាសនៈ រីឯគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មិនទទួលបានលទ្ធផលអ្វីទាំងអស់ ជាមួយអាសនៈនៅសល់ចំនួន ១៣ ដែលត្រូវធ្វើការចាប់ឆ្នោតរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលមានសម្លេងឆ្នោតស្មើគ្នា។


**<u>ទីស្នាក់ការកណ្ដាល</u>** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**<u>Central Office</u> : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

# តារាងប៉ាន់ប្រមាណចំនួនអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុងស្រុកខណ្ឌ

<table>
<tr><th rowspan="4">ល.រ</th><th rowspan="4">ឈ្មោះគណបក្សនយោបាយ</th><th rowspan="4">ស្ថានភាពគណបក្ស</th><th colspan="12">លទ្ធផលបោះឆ្នោតក្រុមប្រឹក្សា</th></tr>
<tr><th colspan="6">ក្រុង ស្រុក និង ខណ្ឌ</th><th colspan="6">រាជធានី ខេត្ត</th></tr>
<tr><th colspan="2">ធម្មតា</th><th colspan="2">បញ្ចូលគ្នាករណីទី១</th><th colspan="2">បញ្ចូលគ្នាករណីទី២</th><th colspan="2">ធម្មតា</th><th colspan="2">បញ្ចូលគ្នាករណីទី១</th><th colspan="2">បញ្ចូលគ្នាករណីទី២</th></tr>
<tr><th>សម្លេង</th><th>អាសនៈ</th><th>សម្លេង</th><th>អាសនៈ</th><th>សម្លេង</th><th>អាសនៈ</th><th>សម្លេង</th><th>អាសនៈ</th><th>សម្លេង</th><th>អាសនៈ</th><th>សម្លេង</th><th>អាសនៈ</th></tr>
<tr><td>១</td><td>គណបក្សប្រជាជន</td><td>ឈរឈ្មោះ</td><td>8292</td><td>2216</td><td>8292</td><td>2211</td><td>8292</td><td>2208</td><td>8292</td><td>305</td><td>8292</td><td>305</td><td>8292</td><td>305</td></tr>
<tr><td>២</td><td>គណបក្សហ៊្វុនស៊ិនប៉ិច</td><td>ឈរឈ្មោះ</td><td>151</td><td>19</td><td rowspan="2">203</td><td rowspan="2">26</td><td>151</td><td>19</td><td>151</td><td>2</td><td rowspan="2">203</td><td rowspan="2">2</td><td>151</td><td>2</td></tr>
<tr><td>៣</td><td>គណបក្សជាតិនិយម</td><td>មិនឈរឈ្មោះ</td><td>52</td><td>1</td><td rowspan="2">3007</td><td rowspan="2">690</td><td>52</td><td>0</td><td rowspan="2">3007</td><td rowspan="2">86</td></tr>
<tr><td>៤</td><td>គណបក្សសង្គ្រោះជាតិ</td><td>ឈរឈ្មោះ</td><td>2955</td><td>679</td><td>2955</td><td>679</td><td>2955</td><td>86</td><td>2955</td><td>86</td></tr>
<tr><td>៥</td><td>គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ</td><td>ឈរឈ្មោះ</td><td>8</td><td>1</td><td>8</td><td>1</td><td>8</td><td>1</td><td>8</td><td>0</td><td>8</td><td>0</td><td>8</td><td>0</td></tr>
<tr><td>៦</td><td>សាធារណរដ្ឋប្រជាធិបតេយ្យ</td><td>ឈរឈ្មោះ</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td><td>0</td></tr>
<tr><td>៧</td><td>សញ្ជាតិកម្ពុជា</td><td>មិនឈរឈ្មោះ</td><td>1</td><td>0</td><td>1</td><td>0</td><td>1</td><td>0</td><td>1</td><td>0</td><td>1</td><td>0</td><td>1</td><td>0</td></tr>
<tr><td colspan="3">សម្លេង និងអាសនៈបានទទួល</td><td>**11459**</td><td>**2916**</td><td>**11459**</td><td>**2917**</td><td>**11459**</td><td>**2918**</td><td>**11459**</td><td>**393**</td><td>**11459**</td><td>**393**</td><td>**11459**</td><td>393</td></tr>
<tr><td colspan="3">សម្លេង និងអាសនៈសរុប</td><td>**11459**</td><td>**2931**</td><td>**11459**</td><td>**2931**</td><td>**11459**</td><td>**2931**</td><td>**11459**</td><td>**393**</td><td>**11459**</td><td>**393**</td><td>**11459**</td><td>**393**</td></tr>
<tr><td colspan="3">អាសនៈនៅសល់</td><td>**0**</td><td>**15**</td><td>**0**</td><td>**14**</td><td>**0**</td><td>**13**</td><td>**0**</td><td>**0**</td><td>**0**</td><td>**0**</td><td>**0**</td><td>**0**</td></tr>
</table>



**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ទោះបីជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាការប៉ាន់ប្រមាណ និងលើកជាករណីដែលអាចកើតមាន ដូចក្នុងករណីខាងលើតែប៉ុណ្ណោះ លទ្ធផលជាក់ស្តែងវាស្ថិតនៅលើសមាជិកក្រុមប្រឹក្សារបស់គណបក្សនិមួយៗ ធ្វើការជ្រើសរើស ដោយអាចមានករណីច្រើនជាងនេះទៀតដូចជា ក្រុមប្រឹក្សាខ្លួនឯង មិនបោះឲ្យគណបក្សខ្លួន ឬត្រូវបានគណបក្សផ្សេងទិញទឹកចិត្តដែលជាហេតុនាំអោយលទ្ធផលរបស់គណបក្សខ្លួនខុសពីការរំពឹងទុក។

## *លទ្ធផលប៉ាន់ប្រមាណនៃការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត*

ខុមហ្វ្រែលក៏បានធ្វើការគណនា រកចំនួនអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងការបោះឆ្នោតអាណត្តិទី ២ ឆ្នាំ២០១៤ ខាងមុខ ដូចលទ្ធផលដែលបានបង្ហាញក្នុងតារាងខាងលើផងដែរ។ លទ្ធផលនៃការគណនារកចំនួនអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈ ៧៧.៦១% (ស្មើ ៣០៥អាសនៈ) នៃអាសនៈសរុបទូទាំងប្រទេស ចំនួន ៣៩៣ រីឯគណបក្សសង្គ្រោះជាតិមានចំនួន ២១.៨៨% (ស្មើ ៨៦អាសនៈ) គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបានចំនួន 0.៥១% (ស្មើ ២អាសនៈ) រីឯគណបក្សជាតិនិយម គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យជាមួយ និងគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មិនទទួលបានអាសនៈក្រុមប្រឹក្សារាជធានីខេត្តក្នុងខេត្តណាមួយនោះទេ។ លទ្ធផលបានបង្ហាញទៀតថា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាមធ្យម ៧៩.៣៤% និងអាសនៈដែលទទួលបានតិចបំផុតក្នុងខេត្តគឺ ៥៧.១៤% ។

បើក្នុងករណីក្រុមប្រឹក្សាឃុំសង្កាត់គណបក្សជាតិនិយម បោះឆ្នោតគាំទ្រ គណបក្សផ្សេងវិញ លទ្ធផលបានបង្ហាញឲ្យឃើញថា គណបក្សទាំងអស់មិនមានអ្វីប្រែប្រួល ច្រើនទេសម្រាប់អាសនៈដែលទទួលបាន ប៉ុន្តែសម្រាប់សម្លេងគាំទ្រធ្វើឲ្យមានការប្រែប្រួល។

ទោះបីគណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សជាតិនិយម និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ចូលគាំទ្រទៅខាងគណបក្សណាមួយ អាចជាគណបក្សប្រជាជនកម្ពុជា ឬគណបក្សសង្គ្រោះជាតិ ក៏លទ្ធផលអាសនៈរបស់គណបក្សទាំងពីរនេះ មិនមានអ្វីប្រែប្រួលច្រើននោះដែរ។ ម៉្យាងទៀត លទ្ធផលជាក់ស្តែងវាអាចមានការប្រែប្រួល បើសិនជាក្រុមប្រឹក្សារបស់គណបក្សខ្លួនមិនបានបោះឆ្នោតឲ្យក្រុមប្រឹក្សារាជធានីខេត្តរបស់ខ្លួន ឬត្រូវបានអ្នកដទៃទិញទឹកចិត្ត។

លទ្ធផលបោះឆ្នោតនេះក៏អាចប្រែប្រួលដោយសារភាពមិនប្រក្រតី ដូចជាការប៉ុនប៉ងទិញសន្លឹកឆ្នោត ផ្តល់សម្ភារៈ ថវិកា ឬ/និង គម្រាមដកតួនាទី ឬផ្តល់តួនាទី ការតម្រូវឱ្យអង្គបោះឆ្នោតធ្វើសម្បថ ឬសច្ចាប្រណិធាន សន្យាបោះឆ្នោតជូនគណបក្សរបស់ខ្លួនក្នុងអំឡុងពេលបោះឆ្នោតក្រុមប្រឹក្សារាជធានីខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ ជាទង្វើ **ខុសច្បាប់បោះឆ្នោតកម្ពុជា** និងខុសគោលការណ៍សកលនៃ **ការគោរពឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោត**។ គណបក្សប្រជាជនកម្ពុជាបានយកចិត្តទុកដាក់ជាមួយសមាជិក ក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន មុនការបោះឆ្នោតនេះខុសពីធម្មតា ដោយសន្យាឲ្យថវិកាចំនួន ១លាន៣ម៉ឺនដុល្លារសម្រាប់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួនសរុបចំនួន ៨២៩២នាក់។



<u>ទីស្នាក់ការកណ្តាល</u> ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ខុមហ្វ្រែល សូមផ្តល់អនុសាសន៍ថា គួរតែធ្វើវិសោធនកម្មច្បាប់លើប្រព័ន្ធបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយដាក់បញ្ចូលជាមួយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងថ្ងៃបោះឆ្នោតតែមួយ ដោយឲ្យមានសន្លឹកឆ្នោតខុសគ្នា និង/ឬយ៉ាងហោចណាស់ប្រព័ន្ធបោះឆ្នោតនេះគួរត្រូវបានបើកចំហរបង្កើនការចូលរួម និងមានតម្លាភាពឱ្យបានច្រើន ដោយបង្កើនអង្គបោះឆ្នោត និងអ្នកបោះឆ្នោតរួមមាន អង្គវិជ្ជាជីវៈ តំណាងកសិករ តំណាងកម្មករ និងតំណាងគ្រូពេទ្យជាដើម។ល។

ក្នុងករណីបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនេះគួរមានសិទ្ធិអំណាចជ្រើសតាំងអភិបាល និងសមាជិកគណៈអភិបាលរបស់ខ្លួន។

**បេសកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។



**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org